CITY OF LONGBEACH

# PRESS RELEASE

**សេចក្តីប្រកាសពត៌មាន**

ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០២០

ទំនាក់ទំនង: មជ្ឈមណ្ឌលពត៌មានរួម សាលាក្រុងឡុងប៊ីឆ, 562.570.NEWS,
jic@longbeach.gov

សំរាប់ផ្សព្វផ្សាយបន្ទាន់

## ការងារលើក្របខ័ណ្ឌការផ្សះផ្សា ឈានឆ្ពោះទៅមុខ

ក្រុងឡុងប៊ីឆ, រដ្ឋកាលីហ្វ័រញ៉ា – មនុស្សជាង ៨០០ នាក់ បានចូលរួមនៅក្នុងវគ្គស្តាប់ ចំនួន ១៥ និងសាលប្រជុំសហគមន៍, ដែលមានរយៈពេលសរុបជាង ៣០ ម៉ោង, ដែលបានរៀបចំឡើងដោយទីក្រុងឡុងប៊ីឆ, ដែលជាផ្នែកមួយ នៃការអភិវឌ្ឍរបស់ខ្លួន នៃក្របខណ្ឌសម្រាប់ការផ្សះផ្សាមួយ។ ដោយទទួលស្គាល់នូវអត្ថិភាព និងផលប៉ះពាល់ជាយូរមកហើយ នៃការរើសអើងជាតិសាសន៍ជាប្រព័ន្ធនៅឡុងប៊ីឆ និងប្រទេស, ការផ្តួចផ្តើមនេះ នឹងផ្តល់នូវក្របខ័ណ្ឌសម្រាប់ការចូលរួមពាក់ព័ន្ធ របស់សាធារណៈជនក្នុងដំណើរការផ្សះផ្សា, ការត្រួតពិនិត្យដំណើរការផ្ទៃក្នុង និងផែនការសកម្មភាពមូលដ្ឋាន។

ចាប់ផ្តើមនៅថ្ងៃទី ១២ ខែមិថុនា, សហគមន៍ក៏ត្រូវបានគេអញ្ជើញ ឱ្យផ្តល់យោបល់ត្រឡប់បន្ថែមទៀត ដើម្បីជួយក្នុងការអភិវឌ្ឍនូវក្របខ័ណ្ឌ តាមរយៈការស្ទង់មតិសហគមន៍មួយ។ រហូតមកដល់ពេលនេះ, មានមនុស្សជាង ២៨០ នាក់ បានឆ្លើយតបទៅនឹងការស្ទង់មតិនេះ ដែលបានបើករហូតដល់ម៉ោង ៥ ល្ងាច ថ្ងៃច័ន្ទ ទី ២០ ខែកក្កដា។ ផងដែរ សាធារណៈជនក៏ត្រូវបានលើកទឹកចិត្ត ឱ្យសួរសំណួរនានា និងផ្តល់ព័ត៌មានបន្ថែម និងអនុសាសន៍បន្ថែមទៀត តាមរយៈអ៊ីម៉ែលទៅកាន់ EquityLB@longbeach.gov.

អភិបាលក្រុង Robert Garcia មានប្រសាសន៍ថា “នេះគឺជាពេលវេលាមួយ នៅក្នុងទីក្រុងរបស់យើង និងប្រវត្តិសាស្ត្ររបស់ប្រទេសយើង ដែលទាមទារអោយមានការទទួលស្គាល់ថា ការរើសអើងជាតិសាសន៍ជាប្រព័ន្ធ មានឥទ្ធិពលទៅលើសហគមន៍នានា ដែលមានពណ៌សម្បុរ”។ “ខ្លួនខ្ញុំផ្ទាល់ និងក្រុមប្រឹក្សាក្រុងរបស់យើង, រួមជាមួយអ្នកគ្រប់គ្រងទីក្រុងរបស់យើង, បានចាត់ទុកសមធម៌ និងយុត្តិធម៌ពូជសាសន៍ ជាអាទិភាព, ហើយយើងមានបំណង ដើម្បីអនុវត្តតាមការសន្យានេះ”។

ការិយាល័យសមធម៌ — ដែលត្រូវបានបង្កើតឡើង ដោយនាយកដ្ឋានសុខាភិបាល និងសេវាមនុស្សក្រុងឡុងប៊ីឆ នៅឆ្នាំ ២០១៧ — ទទួលស្គាល់នូវតម្រូវការបន្ទាន់ ក្នុងការផ្តួចផ្តើមការស្តាប់មតិយោបល់ត្រឡប់របស់សហគមន៍ ជាមួយនឹងការផ្លាស់ប្តូរវប្បធម៌ស្ថាប័ន និងការផ្លាស់ប្តូររចនាសម្ព័ន្ធ, ដូច្នេះដំរុញអោយមានការសន្ទនាជាតិសាសន៍នៅផ្នែកខាងក្នុង ជាមួយបុគ្គលិកទីក្រុងឡុងប៊ីឆ ដើម្បីកំណត់របៀបបង្កើត ឬរៀបចំប្រព័ន្ធនានា ដែលឆ្លុះបញ្ចាំងដល់ឧត្តមប្រយោជន៍នៃរាល់សមាជិកសហគមន៍ទាំងអស់របស់យើង។

អ្នកគ្រប់គ្រងក្រុង លោក Tom Modica មានប្រសាសន៍ថា "វាជាការសំខាន់ណាស់ ដែលក្រុមថ្នាក់ដឹកនាំរបស់យើង ពិតជាស្តាប់ និងឮនូវបទពិសោធន៍ នៃភាពអយុត្តិធម៌ជាតិសាសន៍ និងអនុសាសន៍នានា ស្តីពីវិធីដោះស្រាយផលប៉ះពាល់ជាប្រចាំរបស់រដ្ឋាភិបាល, ប្រព័ន្ធសេដ្ឋកិច្ច និងសង្គម ដែលបានដកចេញជារចនាសម្ព័ន្ធនូវជនជាតិស្បែកខ្មៅ និងជនជាតិដើមភាគតិច និងជនជាតិដែលមានពណ៌សម្បុរផ្សេងៗគ្នានៅឡុងប៊ិច"។ "ការឈឺចាប់ដែលយើងកំពុងមើលឃើញពីសហគមន៍របស់យើង គឺពិត ហើយចាំបាច់ត្រូវអោយគេបានឮ និងបានត្រូវដោះស្រាយដោយសកម្មភាពផ្ទាល់"។

ក្រុងនេះកំពុងចាប់ដៃគូជាមួយ Dr. Amber Johnson មកពីសាកលវិទ្យាល័យរដ្ឋកាលីហ្វ័រញ៉ា, នៅឡុងប៊ីឆ, ដើម្បីវិភាគព័ត៌មានដែលប្រមូលបានក្នុងពេលស្តាប់ និងការប្រជុំនានាតាមសហគម។ Dr. Johnson ជាជំនួយការសាស្ត្រាចារ្យ នៅនាយកដ្ឋានវិទ្យាសាស្ត្រសុខាភិបាល និងមានបទពិសោធន៍យ៉ាងទូលំទូលាយ ក្នុងការស្រាវជ្រាវវិសមភាពសុខភាពពូជសាសន៍ នៅទូទាំង ឬនៅគ្រប់អាយុកាលទាំងអស់។ កង្វល់ និងយុទ្ធសាស្ត្រនានា ដែលបានលើកឡើងដោយអ្នកចូលរួមទាំងឡាយ នឹងជូនដំណឹងដល់គោលនយោបាយចុងក្រោយ, ថវិការ និងអនុសាសន៍សំរាប់កម្មវិធី។

នៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០២០, ក្រុមប្រឹក្សាក្រុងឡុងប៊ីឆ បានទទួលស្គាល់ការរើសអើងជាតិសាសន៍ថាជាវិបត្តិសុខភាពសាធារណៈ និងបានអនុម័តនូវក្របខ័ណ្ឌសម្រាប់ការផ្សះផ្សា ដែលរួមមាន ៤ ជំហ៊ានដូចខាងក្រោមនេះ:

- ការទទួលស្គាល់នូវអត្ថិភាព និងផលប៉ះពាល់ជាយូរមកហើយ នៃការរើសអើងជាតិសាសន៍ជាប្រព័ន្ធនៅឡុងប៊ីឆ, និងជាពិសេសការប្រឆាំងនឹងការរើសអើងជនជាតិស្បែកខ្មៅ។
- ការស្តាប់នូវសេចក្តីអធិប្បាយរបស់សមាជិកសហគមន៍ និងបទពិសោធន៍នៃវិសមភាព និងគ្រោះថ្នាក់ដែលបណ្តាលមកពី ភាពអយុត្តិធម៌ពូជសាសន៍។

- ការសម្របសម្រួលភាគីពាក់ព័ន្ធនានា ដើម្បីវាយតំលៃមតិយោបល់ត្រឡប់ ពីដំណើរការស្តាប់ និងរៀបចំគោលនយោបាយ, ថវិការ, ធម្មនុញ្ញ និងគំនិតកែទម្រង់កម្មវិធី។
- សកម្មភាពកាតាលីករ ដោយបង្ហាញនូវអនុសាសន៍ភ្លាមៗ, រយៈពេលខ្លី, រយៈពេលមធ្យម និងរយៈពេលវែង សម្រាប់ក្រុមប្រឹក្សាក្រុងពិចារណា។

ចាប់តាំងពី សកម្មភាពរបស់ក្រុមប្រឹក្សាក្រុង, ការិយាល័យសមធម៌ និងភាពជាអ្នកដឹកនាំក្រុង បានចាប់ផ្តើមពីរជំហ៊ាន នៃក្របខ័ណ្ឌដែលមានចំនួនបួនជំហ៊ានៈ ការទទួលស្គាល់ និងការស្តាប់។ ក្រុងនឹងបន្តធ្វើការផ្តោះទៅរក ការកោះប្រជុំអ្នកដែលពាក់ព័ន្ធទាំងឡាយ និងបង្កើតនូវសំណុំអនុសាសន៍មួយ សម្រាប់ធ្វើការពិចារណាដោយក្រុមប្រឹក្សាក្រុង នៅក្នុងខែសីហា។

**អំពីទីក្រុងឡុងប៊ីឆ**

ទីក្រុងឡុងប៊ីឆ មានប្រជាជនប្រមាណ ៤៧០,០០០ នាក់, ជាទីក្រុងដែលទទួលបានពានរង្វាន់យ៉ាងច្រើន និងទីក្រុងប្រកបដោយភាពច្នៃប្រឌិត ផ្តល់ជូននូវភាពឆើតឆាយ ជាទីមនោរម្យសំបូរបែប លំដាប់ពិភពលោកនៃទីក្រុងប្រជុំជនដ៏ធំមួយ ក្នុងខណៈពេលដែលរក្សាបាននូវអារម្មណ៍ដ៏រឹងមាំនៃឯកត្តបុគ្គល និងសង្កាត់ផ្សេងៗ ដែលបានរស់នៅផ្តុំគ្នាយ៉ាងសុខស្រួល នៅតាមបណ្តោយឆ្នេរសមុទ្រកាលីហ្វ័រញ៉ា។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញ, ទីក្រុងឡុងប៊ីឆ ជាផ្ទះរបស់ម្ចាស់ក្សត្រី Queen Mary, អាងចិញ្ចឹមត្រី នៃមហាសមុទ្រប៉ាស៊ីហ្វិក, សារៈមន្ទីរ និងរោងកុន ជាច្រើន, សាលារៀនស្តូលឌីសទ្រីច ដែលត្រូវបានវាយតម្លៃយ៉ាងខ្ពស់, អាកាសយានដ្ឋានឡុងប៊ីឆ និងកំពង់ផែឡុងប៊ីឆ។ ផងដែរ ទីក្រុងនេះក៏មានសាកលវិទ្យាល័យ និងមហាវិទ្យាល័យ ដែលត្រូវបានគេគោរពខ្ពស់, កន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្រ្តពីរ, មន្ទីរពេទ្យចំនួនប្រាំ, ទីលានវាយកូនហ្គោលចំនួនប្រាំ, សួនឧទ្យានចំនួន ១៧១, ឆ្នេរខ្សាច់ជាច្រើនម៉ាយល៍, កំពង់ផែ ឬម៉ារីណា និងផ្លូវជិះកង់។

សម្រាប់ព័ត៌មានបន្ថែម អំពីទីក្រុងឡុងប៊ីឆ, ទស្សនា http://longbeach.gov/. តាមពួកយើង នៅលើបណ្តាញសង្គម ដើម្បីតាមដាន ឬទទួលបាននូវព័ត៌មានថ្មីៗ: Facebook, Twitter, Instagram និង YouTube.

###